ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខៈ ១២៩ MIH / 2015

# ប្រកាស
## ស្តីពី
## បទប្បញ្ញត្តិបច្ចេកទេស CTR 007:2015
## សម្រាប់ការចម្លងភាពកខ្វក់ និងភាពពុលក្នុងម្ហូបអាហារ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីស្តង់ដារកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ ១៤១ MIH/2014 ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រុមប្រឹក្សាស្តង់ដារជាតិ
- យោងរបាយការណ៍នៃកិច្ចប្រជុំលើកទី១៣ របស់ក្រុមប្រឹក្សាស្តង់ដារជាតិ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥

### សម្រេច

**ប្រការ១ ៖** កំណត់បទប្បញ្ញត្តិបច្ចេកទេស CTR 007:2015 សម្រាប់ការចម្លងភាពកខ្វក់ និងភាពពុលក្នុងម្ហូបអាហារ ដែលតម្រូវឲ្យបុគ្គលណាមួយដែលផលិត កែច្នៃ នាំចូល ផ្សព្វផ្សាយពាណិជ្ជកម្មលក់ ឬ លក់ផលិតផលម្ហូបអាហារ ត្រូវអនុលោមតាមស្តង់ដារកម្ពុជា CS 078:2012 សម្រាប់ការចម្លងភាពកខ្វក់ និងភាពពុលក្នុងម្ហូបអាហារ ក្នុងគោលបំណងធ្វើឲ្យកាន់តែប្រសើរឡើងនូវគុណភាពផលិតផល ធានាបាននូវសុវត្ថិភាពដល់អ្នកប្រើប្រាស់ និងលើកកម្ពស់សុខមាលភាពសាធារណៈ។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខៈ (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខៈ (៨៥៥) ២៣ ៤២៨ ២៦៣
អ៊ីម៉ែលៈ mih.smcabinet@gmail.com

**<u>ប្រការ២</u>៖** បុគ្គលណាមួយដែលផលិត កែច្នៃ នាំចូល ផ្សព្វផ្សាយពាណិជ្ជកម្មលក់ ឬ លក់ផលិតផលម្ហូបអាហារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសដូចមានចែងក្នុងប្រការ១ ខាងលើជាដាច់ខាត និងត្រូវមានអាជ្ញាប័ណ្ណ និងមានបិទសញ្ញាស្តង់ដារកម្ពុជា (សញ្ញាចុះបញ្ជីផលិតផល) នៅលើសំបកវេចខ្ចប់ផលិតផល។

**<u>ប្រការ៣</u>៖** ក្នុងករណីផលិតផលម្ហូបអាហារ មិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសដូចមានចែងក្នុងប្រការ១ ខាងលើ ឬមិនមានបិទ ឬ បោះពុម្ពសញ្ញាស្តង់ដារកម្ពុជា (សញ្ញាចុះបញ្ជីផលិតផល) នៅលើ សំបកវេចខ្ចប់ ផលិតផល ដែលធ្វើចរាចរនៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា រូបវន្តបុគ្គល ឬនីតិ បុគ្គល ដែលផលិត កែច្នៃ នាំចូល ផ្សព្វផ្សាយពាណិជ្ជកម្មលក់ ឬ លក់ផលិតផលម្ហូបអាហារនោះ ត្រូវផ្តន្ទាទោសតាមច្បាប់ ស្តីពីស្តង់ដារកម្ពុជា។

**<u>ប្រការ៤</u>** ៖ បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**<u>ប្រការ៥</u>** ៖ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល អគ្គាធិការ ប្រធាននាយកដ្ឋាន បញ្ញត្តកម្ម ប្រធាននាយកដ្ឋាននីតិកម្ម ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី-ខេត្ត និងអង្គភាព ក្រោមឱវាទក្រសួង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**<u>ប្រការ៦</u>** ៖ ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តបន្ទាប់ពីរយៈពេល ៦០ថ្ងៃ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១៥

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**<u>កន្លែងទទួល</u>** ៖

- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ គាត ឈន់
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័នមានតំណាងជាសមាជិកក្រុមប្រឹក្សាស្តង់ដារជាតិ
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ